ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម
លេខ ៖ ៩៩៤ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០៩

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការអនុវត្តកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៤ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការចាត់តាំងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មិនា ឆ្នាំ ២០០៦ ស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ
- បានឃើញអនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការដាក់ឲ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ ⁄

- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៨ ស្តីពីការដំឡើងនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរណ៍-អាហរណ៍ និងបង្ក្រាបការក្លែងបន្លំ(កាំកុងត្រូល) ទៅជាអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរណ៍-អាហរណ៍ និងបង្ក្រាប ការក្លែងបន្លំ (កាំកុងត្រូល) ចំណុះក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការដំឡើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ ទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១០១៩ សហវ.ប្រក.គរ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបង្កើតក្រុមសម្របសម្រួលអន្តរស្ថាប័ន នៃកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ
- យោងតាមសំណូមពរការងារចាំបាច់

**សម្រេច**

**ប្រការ១:**

ប្រកាសអន្តរក្រសួងនេះមានគោលបំណងរៀបចំជាផ្លូវការ នូវយន្តការអនុវត្តគោលនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីរៀបចំការសម្របសម្រួលការងាររវាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា (ហៅកាត់ថា អគរ) នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យនីហរណ៍-អាហរណ៍ និងបង្ក្រាបការក្លែងបន្លំ (ហៅកាត់ថា កាំកុងត្រូល) នៃក្រសួងពាណិជ្ជកម្ម តាមបញ្ញត្តិអនុក្រឹត្យស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ និងបទប្បញ្ញត្តិច្បាប់ជាធរមានផ្សេងទៀតដែលត្រូវបញ្ជាក់ពីតួនាទី ការទទួលខុសត្រូវ និងទម្រង់នៃកិច្ចសហការរបស់អគ្គនាយកដ្ឋានទាំងពីរដើម្បីធានាប្រសិទ្ធភាព នៃការគ្រប់គ្រងត្រួតពិនិត្យប្រតិបត្តិការនាំចូល នាំចេញទំនិញ នៅតាមមាត់ច្រកព្រំដែននានានៃព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកលើគម្រូអនុវត្តល្អបំផុតជាអន្តរជាតិ និងមានបទដ្ឋានរដ្ឋបាលច្បាស់លាស់។

**ប្រការ ២:**

កំណត់ទីកន្លែងទំនាក់ទំនងព័ត៌មានដូចខាងក្រោម៖

ក. សម្រាប់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា:

- អង្គភាព: នាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ:

- មន្ត្រី: លោក ប៉ែន សំអាត ឋានៈ ប្រធាននាយកដ្ឋាន
ទូរស័ព្ទលេខ: (៨៥៥) ១២ ៣២៩ ៣២៩ ទូរសារលេខ: (៨៥៥) ២៣ ២១២ ០២៥ និងសារអេឡិចត្រូនិក: psa@camnet.com.kh។

ខ. សម្រាប់អគ្គនាយកដ្ឋានកាំកុងត្រូល ⁄

-អង្គភាព: នាយកដ្ឋានកិច្ចការការពារអ្នកប្រើប្រាស់ និងបង្ក្រាបការក្លែងបន្លំ
-មន្ត្រី: លោក គឹម មាសសុខសីហា ឋានៈ ប្រធាននាយកដ្ឋាន
ទូរស័ព្ទលេខ: (៨៥៥) ១២ ៣៨៧ ៨៧៨ ទូរសារលេខ: (៨៥៥) ២៣ ៤២៦ ១៦៦ និង សារអេឡិកត្រូនិក: ccd_seiha@yahoo.com ។

**ប្រការ ៣:**

កំណត់ភារកិច្ចរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (ហៅកាត់ថា អគរ) សម្រាប់ការចូលរួមអនុវត្តគោលនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ ដូចតទៅ ៖

១. ជាស្ថាប័ននាំមុខតែមួយគត់ ដែលទទួលខុសត្រូវលើការត្រួតពិនិត្យទំនិញនៅមាត់ច្រកអន្តរជាតិ ។ ក្នុងករណីតម្រូវឲ្យមានការចូលរួមត្រួតពិនិត្យដោយស្ថាប័នផ្សេងទៀត អគរ ត្រូវសម្របសម្រួលដល់ការត្រួតពិនិត្យឲ្យធ្វើឡើងរួមគ្នាតែមួយលើក ស្របតាមបញ្ញត្តិមាត្រា ៥ ជំពូក ២ នៃអនុក្រឹត្យស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ ។

២. នៅកាលៈទេសៈសមស្រប ជាពិសេសនៅទីកន្លែងដែលប្រព័ន្ធគ្រប់គ្រងហានិភ័យ និង/ឬ ប្រព័ន្ធ ASYCUDA ពុំទាន់ត្រូវបានដាក់ឲ្យដំណើរការ ត្រូវចាត់ចែងឲ្យមានការធ្វើសកម្មភាពរួមគ្នាក្នុងការត្រួតពិនិត្យ និងវាយតម្លៃលើឯកសារ ឬត្រួតពិនិត្យរូបវន្តលើទំនិញនាំចូល នាំចេញ ដែលស្ថិតក្រោមសមត្ថកិច្ចគ្រប់គ្រងគោលនយោបាយរបស់កាំកុងត្រូល ប្រសិនបើមានការតម្រូវ។

៣. នៅកាលៈទេសៈសមស្រប ជាពិសេសនៅទីកន្លែងដែលប្រព័ន្ធគ្រប់គ្រងហានិភ័យ និង/ឬ ប្រព័ន្ធ ASYCUDA ពុំទាន់ត្រូវបានដាក់ឱ្យដំណើរការ ត្រូវចាត់ចែងឲ្យមានការចុះហត្ថលេខារួមគ្នាលើសេចក្តីសំរេចបញ្ចេញទំនិញដោយគ្មានការធ្វើអធិការកិច្ចរូបវន្តលើទំនិញ ស្របតាមសេចក្តីណែនាំរដ្ឋបាល ដែលត្រូវបង្កើតឡើងដោយក្រុមសម្របសម្រួលអន្តរស្ថាប័ន តាមបញ្ញត្តិមាត្រា ៦ នៃអនុក្រឹត្យស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ។

៤. អនុវត្តតាមបញ្ញត្តិអនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការដាក់ឲ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ ព្រមទាំងមានការកិច្ចសម្របសម្រួល សហការអនុវត្តតាមសំណើកែតម្រូវ ឬបំពេញបន្ថែមបញ្ជីនេះ ក្រោយពីបានទទួលការសំរេចពីរាជរដ្ឋាភិបាលកម្ពុជា ។

៥. ក្នុងករណីតម្រូវឲ្យមានអ្នកឯកទេសជាក់លាក់ ដែលមិនមាននៅ អគរ និង កាំកុងត្រូល មន្ត្រី អគរ មានសមត្ថកិច្ច ត្រូវស្នើសុំអ្នកឯកទេសពីស្ថាប័នពាក់ព័ន្ធមកចូលរួមក្នុងដំណើរការត្រួតពិនិត្យរូបវន្ត ។

៦. អគរ ត្រូវសហការផ្លាស់ប្តូរទិន្នន័យ ឬសូចនាករទំនិញនាំចេញ នាំចូល ឬធុរជនពាក់ព័ន្ធនានាជាមួយ កាំកុងត្រូល តាមទីកន្លែងដូចមានចែងក្នុងប្រការ ២ នៃប្រកាសអន្តរក្រសួងនេះ ។

៧. អគរ ត្រូវផ្សព្វផ្សាយដល់ កាំកុងត្រូល នូវបទបញ្ញត្តិ និងរាល់ការវិវត្តិពាក់ព័ន្ធដល់កិច្ចដំណើរការអនុវត្តគោលនយោបាយ នៃកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ និងត្រូវសម្របសម្រួលជាមួយ កាំកុងត្រូល ក្នុងការធ្វើអង្កេត ការវាយតម្លៃនិងការធ្វើចំណាត់ថ្នាក់ ធុរជន ឬទំនិញតាមកម្រិតហានិភ័យ លើធុរជន និងទំនិញ ដែលស្ថិតក្រោមសមត្ថកិច្ចគ្រប់គ្រងគោលនយោបាយរបស់ កាំកុងត្រូល ដោយរក្សាឲ្យបាននូវការសម្ងាត់វិជ្ជាជីវៈ ។

**ប្រការ ៤:**

កំណត់ភារកិច្ចរបស់កាំកុងត្រូល សម្រាប់ការចូលរួមអនុវត្តគោលនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ ដូចតទៅ ៖

១. កាំកុងត្រូល ត្រូវបញ្ជូនបញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ដែលបានធ្វើបច្ចុប្បន្នភាព និងបានការសម្រេចពីរាជរដ្ឋាភិបាលកម្ពុជាជាយថាហេតុមក អគរ ដើម្បីធ្វើចំណាត់ថ្នាក់ទំនិញតាមប្រព័ន្ធស៊ីចង្វាក់នៃតារាងពន្ធគយកម្ពុជាជាធរមាន ដើម្បីចាត់ចែងអនុវត្តអោយមានប្រសិទ្ធភាព និង/ឬបញ្ចូលទៅក្នុងម៉ូឌុលការគ្រប់គ្រងហានិភ័យនៃស្វ័យប្រវត្តិកម្មទិន្នន័យគយ (ASYCUDA) ។

២. កាំកុងត្រូល ត្រូវបញ្ជូនព័ត៌មានពីទំនិញ ឬមុខសញ្ញាធុរជនដែលជាប់ហានិភ័យខ្ពស់ ដែលជាលទ្ធផលនៃការធ្វើអង្កេតវាយតម្លៃរបស់អង្គភាពគ្រប់គ្រងហានិភ័យរបស់ កាំកុងត្រូល ឬពី ប្រភពព័ត៌មានសម្ងាត់ផ្សេងទៀតដែលទទួលបានជាបន្ទាន់ មក អគរ ដើម្បីចាត់វិធានការបានទាន់ពេល ។ ប្រសិនបើ កាំកុងត្រូល យល់ថាចាំបាច់ ត្រូវធ្វើការកំណត់និងបញ្ជាក់ពីសកម្មភាពដែល អគរ ត្រូវអនុវត្តក្នុងការត្រួតពិនិត្យទំនិញដែលឆ្លងកាត់នៅតាមបណ្តាមាត់ច្រកព្រំដែន ឬតម្រូវការចូលរួមត្រួតពិនិត្យរូបវន្តរបស់ កាំកុងត្រូល ជាយថាហេតុលើជើងដឹកជញ្ជូនណាមួយ ក្រោមការសម្របសម្រួលរបស់ អគរ ។

៣. កាំកុងត្រូល ត្រូវចូលរួមជាមួយ អគរ ធ្វើអធិការកិច្ចរូបវន្តលើទំនិញ ដែលស្ថិតក្រោមសមត្ថកិច្ចគ្រប់គ្រងគោលនយោបាយរបស់ កាំកុងត្រូល ប្រសិនបើមានការតម្រូវឲ្យចូលរួមក្រោមការសម្របសម្រួលរបស់ អគរ និងស្របតាមសេចក្តីណែនាំរដ្ឋបាល ដែលត្រូវបង្កើតឡើងដោយក្រុមសម្របសម្រួលអន្តរស្ថាប័នស្របតាមបញ្ញត្តិមាត្រា ៦ នៃអនុក្រឹត្យលេខ ២១អនក្រ.បក ដូចយោងខាងលើ ។

៤. ក្នុងកាលៈទេសៈសមស្រប ជាពិសេសនៅទីកន្លែងដែលប្រព័ន្ធគ្រប់គ្រងហានិភ័យ និង/ឬប្រព័ន្ធ ASYCUDA ពុំទាន់ត្រូវបានដាក់ឲ្យដំណើរការ ចូលរួមត្រួតពិនិត្យលើឯកសារនាំចេញនាំចូល និងចុះហត្ថលេខាលើសេចក្តីសម្រេចបញ្ចេញទំនិញពីគយ ដោយគ្មានការត្រួតពិនិត្យរូបវន្តលើទំនិញ ស្របតាមសេចក្តីណែនាំរដ្ឋបាល ដែលត្រូវបានបង្កើតឡើងដោយក្រុម/

សម្របសម្រួលអន្តរស្ថាប័នស្របតាមបញ្ញត្តិមាត្រា ៦ នៃអនុក្រឹត្យលេខ ២១ អនក្រ.បក ដូចយោងខាងលើ ។

**ប្រការ ៥:**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកកាំកុងត្រូល អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធផ្សេងទៀតនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តតាមប្រកាសអន្តរក្រសួងនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម-ប្រសិទ្ធ**

**ចម្លងជូន ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- អគ្គនាយកដ្ឋានកាំកុងត្រូល
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីសហការផ្សព្វផ្សាយ"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ